**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៩ ស.សរ**

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្ដម ម៉ែន យ៉េត រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរ និង ការងារចាំបាច់

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការចំរុះមួយ ដើម្បីរៀបចំបុណ្យសពឯកឧត្ដម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១_អ្នកអង្គម្ចាស់ | ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ | ប្រធាន |
| ២_ឯកឧត្ដម | អ៊ុក សុជាតិ | អនុប្រធាន |
| ៣_ឯកឧត្ដម | ជា គាន | អនុប្រធាន |
| ៤_ឯកឧត្ដម | សេង លឹមនៅ | សមាជិក |
| ៥_ឯកឧត្ដម | ប៊ុន សំ | សមាជិក |
| ៦_ឯកឧត្ដម | យូ ស៊ីនឡុង | សមាជិក |
| ៧_ឯកឧត្ដម | ជា សុខុម | សមាជិក |
| ៨_ឯកឧត្ដម | ហ៊ុល ផានី | សមាជិក |
| ៩_ឯកឧត្ដម | ឃឹម សារិទ្ធ | សមាជិក |
| ១០_ឯកឧត្ដម | ម៉ប់ សារិន | សមាជិក |

១១_ឯកឧត្តម ទុយ គឿន សមាជិក
១២_ឯកឧត្តម ជីង ឈង សមាជិក
១៣_ឯកឧត្តម ឥត សារ៉ាត់ សមាជិក
១៤_ឯកឧត្តម តែ គុយស៊ាង សមាជិក
១៥_លោក បួន លីមហេង សមាជិក
១៦_លោក គង់ សារ៉ាន់ សមាជិក
១៧_លោក គីម សុផាណា សមាជិក

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ច :

_ទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម **ម៉ែន យ៉េត** រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អោយបានល្អប្រសើរ ស្របតាមប្រពៃណីជាតិ ។

_រៀបចំកម្មវិធីលំអិតសំរាប់បុណ្យសព ពិធីការ ទទួលភ្ញៀវជាតិ អន្តរជាតិ ដែលត្រូវអញ្ជើញគោរពវិញ្ញាណក្ខន្ធសព រៀបចំវិយោគកថា និងឯកសារផ្សេងៗដែលចាំបាច់ ។

_រៀបចំពិធីបូជាបូជាសពតាមប្រពៃណីសាសនា និងប្រពៃណីជាតិ ដោយសហការជិតស្និទ្ធជាមួយគ្រួសារសព ។

_ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។

_រៀបចំក្បួនដង្ហែសព និងពិធីបូជាសពអោយល្អប្រសើរ ។

_គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការមួយចំនួនទៀត តាមតំរូវការចាំបាច់ ដើម្បីជាជំនួយការ ។

_គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

_សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៣** : ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ_អន្តរជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាម សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ_កាលប្បវត្តិ